## ស្ថានទូតជប៉ុន

## ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ. 28 PR-17/EoJ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧

**ជប៉ុនផ្តល់ថវិកាសរុប ១,៥៦១,៨០៥ ដុល្លារអាមេរិក**
**សម្រាប់ការសាងសង់ស្ពានដើម្បីអភិវឌ្ឍន៍ជនបទ**
**ការលើកកម្ពស់និរន្តរភាពនៃស្ថានភាពកសិកម្មដើម្បីកាត់បន្ថយភាពក្រីក្រ**
**និងការលើកកម្ពស់ការអភិវឌ្ឍសហគមន៍តាមរយៈការបោសសម្អាតមីន**

រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ២៤២,៣៦៧ដុល្លារអាមេរិក ដល់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី សម្រាប់ "គម្រោងសាងសង់ស្ពាន២កន្លែង ក្នុងឃុំចំនួនពីរ នៃស្រុកកោះញែក ខេត្តមណ្ឌលគិរី" *ក្រោមគ្រោងការណ៍ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ)* ថវិកាចំនួន ៥៥៨,២៣៦ដុល្លារអាមេរិក ដល់វិទ្យាស្ថានកែលម្អ និងអភិរក្សបរិស្ថាន (អង្គការERECON) សម្រាប់ "គម្រោងលើកកម្ពស់និរន្តភាពនៃស្ថានភាពកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងខេត្តកំពង់ចាម" និងថវិកាចំនួន ៧៦១,២០២ដុល្លារអាមេរិក ដល់អង្គការសកម្មភាពកម្ចាត់មីនជប៉ុន (អង្គការJMAS) សម្រាប់ "គម្រោងលើកកម្ពស់ការអភិវឌ្ឍសហគមន៍ តាមរយៈការបោសសម្អាតមីន ក្នុងខេត្តបន្ទាយមានជ័យ" ក្រោមគ្រោងការណ៍ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយទាំងនេះ ត្រូវបានចុះហត្ថលេខាថ្ងៃនេះនៅស្ថានទូតជប៉ុន ដោយឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក យន់ សារ៉ាម ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី បណ្ឌិត MIHARA Machito នាយកអង្គការERECON និងលោក SHIBATA Mikio ប្រធានតំណាងអង្គការJMAS។

សម្រាប់"គម្រោងសាងសង់ស្ពាន២កន្លែង ក្នុងឃុំចំនួនពីរ នៃស្រុកកោះញែក ខេត្តមណ្ឌលគិរី " មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី នឹងសាងសង់ស្ពានចំនួន២ ដែលមួយមានប្រវែង២៤ម៉ែត្រ និងមួយទៀតមានប្រវែង១៨ម៉ែត្រ សម្រាប់ឆ្លងកាត់អូរនៅតាមបណ្តោយផ្លូវលំ ក្នុងស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលជាធម្មតាអ្នកភូមិធ្វើដំណើរតាមទូក ដើម្បីឆ្លងកាត់អូរទាំងនេះនៅរដូវវស្សា។ គម្រោងនេះ ត្រូវបានរំពឹងថា នឹងផ្តល់ភាពងាយស្រួល និងសុវត្ថិភាពប្រសើរជាងមុន ដល់អ្នកភូមិប្រមាណជា ៦,០០០នាក់ ក្នុងការធ្វើដំណើរឆ្លងកាត់ទៅកាន់សាលារៀន មន្ទីរពេទ្យ និងផ្សារ ព្រមទាំងជួយសម្រួលដល់ការប្រកបអាជីវកម្មរបស់ពួកគេផងដែរ។

សម្រាប់"គម្រោងលើកកម្ពស់និរន្តរភាពនៃស្ថានភាពកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រ ក្នុងខេត្តកំពង់ចាម" អង្គការ ERECON នឹងជំរុញអោយមានការដាំដំណាំប្រកបដោយនិរន្តរភាព តាមរយៈការកែលម្អស្ថានភាពដីដោយវិធីសាស្ត្រនានាដែលមិនប៉ះពាល់ដល់បរិស្ថាន ដោយធ្វើការសហការជាមួយនឹងមន្ត្រីផ្នែកកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ស្ថាប័នស្រាវជ្រាវនៅសាកលវិទ្យាល័យនានា និងប្រជាកសិករ។ តាមរយៈការលើកកម្ពស់និរន្តរភាពនៃស្ថានភាពកសិកម្មជាគំរូ គម្រោងនេះ ត្រូវបានរំពឹងថា នឹងកែលម្អគុណភាពនៃការផលិត និងកសិផល ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករ និងជំរុញអោយមានការផ្គត់ផ្គង់ស្បៀងប្រកបដោយសុខសុវត្ថិភាពនៅលើទីផ្សារផងដែរ។

សម្រាប់"គម្រោងលើកកម្ពស់ការអភិវឌ្ឍសហគមន៍តាមរយៈការបោសសម្អាតមីន ក្នុងខេត្តបន្ទាយមានជ័យ" អង្គការ JMAS នឹងផ្ទេរវិធីសាស្ត្របញ្ចូលគ្នា ក្នុងការបោសសម្អាតមីន ដល់មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា(CMAC) តាមរយៈការបាត់ការនៅចម្ការមីន ក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដើម្បីអាចអោយCMACប្រើប្រាស់ជំនាញខ្ពស់សម្រាប់ប្រតិបត្តិការបោសសម្អាតមីនប្រកបដោយភាពម្ចាស់ការនៅក្នុងស្ថានភាពលំបាក។ អង្គការJMAS ក៏នឹងជួយ CMAC ក្នុងការផ្សព្វផ្សាយចំណេះដឹងអំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់អ្នកភូមិដែលរស់នៅក្នុងតំបន់គោលដៅ ដើម្បីការពារពួកគេអោយរួចផុតពីគ្រោះថ្នាក់ដោយសារមីន។

*ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា៖ ភាពក្រីក្រ និងភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៦.៧លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៧២ គម្រោងនៅទូទាំងប្រទេសកម្ពុជា។ គម្រោងរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី គឺជាគម្រោងទី១ ដែលផ្តល់ជូនដោយគ្រោងការណ៍នៃជំនួយនេះនៅកម្ពុជាសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៧របស់ជប៉ុន (មេសា ២០១៧ ដល់ មីនា ២០១៨)។

*ជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង ៣០.២លានដុល្លារអាមេរិក ដល់គម្រោងចំនួន ១០៣គម្រោង ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីន។ គម្រោងរបស់ERECON គឺជាគម្រោងទី៣ ហើយគម្រោងរបស់អង្គការJMAS គឺជាគម្រោងទី៤ ដែលបានផ្តល់ជូនដោយគ្រោងការណ៍នៃជំនួយនេះនៅកម្ពុជាសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៧របស់ជប៉ុន (មេសា ២០១៧ ដល់មីនា ២០១៨)៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៦-៣៣០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*